# សេចក្តីប្រកាសព័ត៌មាន

សំរាប់ការផ្សាយបន្ទាន់

ថ្ងៃច័ន្ទ ទី២៨ ខែសីហា ឆ្នាំ២០០៦

## តំបន់អាស៊ី និង ប៉ាស៊ីហ្វិក ប្រឈមនឹងគំលាតការងារយ៉ាងធ្ងន់ធ្ងរ

## កិច្ចប្រជុំប្រចាំតំបន់របស់អង្គការពលកម្មអន្តរជាតិ ដើម្បីពិភាក្សាពីយុទ្ធសាស្ត្រថ្មីៗ សំដៅបង្កើតការងារប្រកបដោយផលិតភាព ការងារថ្លៃថ្នូរ និង កាត់បន្ថយភាពក្រីក្រ

ប៊ូសាន សាធារណៈរដ្ឋកូរ៉េ (ព័ត៌មានរបស់អង្គការពលកម្មអន្តរជាតិ) – កំណើនយ៉ាងឆាប់រហ័សខាងការធ្វើពាណិជ្ជកម្ម ការវិនិយោគទុន និង ទិន្នផល ខកខានមិនបានដើរអោយទាន់កំណើននៃកំលាំងការងារ និងមិនបានដោះស្រាយដោយជោគជ័យលើកំនើនភាពគ្មានការងារធ្វើនៅអាស៊ី និង ប៉ាស៊ីហ្វិកនោះទេ ដែលមានកម្មករនិយោជិតប្រហែលជា ២៥០ លាននាក់បន្ថែមទៀត ត្រូវបានគេរំពឹងថានឹងស្វែងរកការងារធ្វើនៅក្នុងទសវត្សបន្ទាប់ នេះបើតាមរបាយការណ៍ថ្មីមួយ ដែលចេញដោយអង្គការពលកម្មអន្តរជាតិ (ILO) ។

របាយការណ៍ក្រោមចំណងជើងថា "សំរេចអោយបាននូវការងារថ្លៃថ្នូរនៅអាស៊ី"[១] ដែលរៀបចំឡើងសំរាប់កិច្ចប្រជុំប្រចាំតំបន់លើកទី ១៤ របស់អង្គការពលកម្មអន្តរជាតិ ដែលនឹងប្រព្រឹត្តិឡើងពីថ្ងៃទី ២៩ សីហា ដល់ ថ្ងៃទី ១ កញ្ញា បានលើកឡើងថា តំបន់នេះបានបោះជំហានសេដ្ឋកិច្ចយ៉ាងវែងគួរអោយកត់សំគាល់ ហើយឥលូវនេះ កាន់កាប់ "មុខតំណែងទី ១ នៅក្នុងសេដ្ឋកិច្ចសកល" ។

យ៉ាងណាក៏ដោយ ខណៈពេលដែលប្រទេសជាច្រើននៅក្នុងតំបន់ បានសំរេចសមិទ្ធិផលយ៉ាងធំធេងក្នុងការកាត់បន្ថយភាពក្រីក្រ "ប្រជាជនក្រីក្រដែលកំពុងធ្វើការ" ជាង ១ ពាន់លាននាក់ កំពុងរស់នៅក្រោមបន្ទាត់ក្រីក្រជាមួយនឹងចំណូលតិចជាង ២ ដុល្លា សំរាប់មនុស្សម្នាក់ក្នុងមួយថ្ងៃ ដែលក្នុងនោះរួមមានមនុស្សជាង ៣៣០ លាននាក់ កំពុង

---

[១] *"សំរេចអោយបាននូវការងារថ្លៃថ្នូរ" របាយការណ៍រៀបរៀងដោយអគ្គនាយក សំរាប់កិច្ចប្រជុំប្រចាំតំបន់លើកទី ១៤ នៅប៊ូសាន កូរ៉េ ពីថ្ងៃខែសីហា-កញ្ញា ២០០៦* ISBN 978-92-2-118770-7 *អាចរកបាននៅលើអ៊ីនធឺណិត (ភាសាអង់គ្លេស) តាមរយៈ:* http://www.ilo.org/public/english/standards/relm/rgmeet/14asrm/dgrealizing.pdf *របាយការណ៍ផ្លូវការនេះបំពេញបន្ថែមដោយ របាយការណ៍ព័ត៌មានមួយ ដែលផ្តល់ទិន្នន័យ និង ការវិភាគលំអិត ទៅលើល័ក្ខខ័ណ្ឌការងារ និង សង្គមរបស់តំបន់នេះ: "និន្នាការការងារ និង សង្គម នៅអាស៊ី និង ប៉ាស៊ីហ្វិក ឆ្នាំ២០០៦ វឌ្ឍនភាពឆ្ពោះទៅរកការងារថ្លៃថ្នូរ រៀបចំដោយការិយាល័យប្រចាំតំបន់សំរាប់អាស៊ី និង ប៉ាស៊ីហ្វិក* ISBN 92-2-119039-0 ។

រស់នៅក្នុងភាពក្រីក្របំផុត ដែលមានចំណូលតិច ជាង ១ ដុល្លាក្នុងមួយថ្ងៃ។ បន្ថែមលើសពីនេះ អត្រាគ្មានការងារធ្វើ បានកើនឡើងក្នុងកំឡុងពេលពេញទាំង ៥ ទៅ ៧ ឆ្នាំមុន នៅបណ្តាប្រទេសភាគច្រើននៅក្នុងតំបន់ ។

លោក Juan Somavia អគ្គនាយកអង្គការពលកម្មអន្តរជាតិ មានប្រសាសន៍ថា "គំលាតរវាងកំណើន និង ការបង្កើតការងារកំពុងបង្កអោយមានឱនភាពការងារថ្លៃថ្នូរ និងរាំងស្ទះដល់កិច្ចខិតខំប្រឹងប្រែងដើម្បីកាត់បន្ថយភាពក្រីក្រ។ បញ្ហាប្រឈមនៃការងារមានសភាពធំធេងណាស់។ កំលាំងការងាររបស់អាស៊ីដែលមានបុរស និង ស្ត្រី ប្រមាណ ១,៩ ពាន់លាននាក់ មានលក្ខណៈធំធេង និង កំពុងកើនឡើងបន្តទៀត យ៉ាងហោចណាស់ ១៤% ឬ ២៥០ លាននាក់ នៅក្នុងរយៈពេល ១០ ឆ្នាំទៅមុខទៀត" ។

ប្រតិភូតំណាងរដ្ឋាភិបាល និយោជក និង និយោជិត មកពីប្រទេសជាសមាជិកអង្គការពលកម្មអន្តរជាតិ ចំនួន ៤០ នៅក្នុងតំបន់នេះ នឹងធ្វើការពិភាក្សាពីបញ្ហាប្រឈមនានាដូចជា ភាពប្រកួតប្រជែង ផលិតភាព និង ការងារថ្លៃថ្នូរនៅក្នុងបរិបទសកលភាវូនីយកម្ម ការងារថ្លៃថ្នូរសំរាប់យុវជន ការគ្រប់គ្រងទេសន្តរប្រវេសន៍ដើម្បី ស្វែងរកការងារធ្វើ អភិបាលកិច្ចទីផ្សារការងារដើម្បីសំរេចអោយបាននូវការងារថ្លៃថ្នូរនៅអាស៊ី និង ពង្រីកកិច្ចការពារសង្គមទៅក្នុងសេដ្ឋកិច្ចក្រៅផ្លូវការ ។ ការពិភាក្សាទាំងនេះ នឹងលើកយកបទដ្ឋាន និង គោលការណ៍និងសិទ្ធិ ជាមូលដ្ឋាននៅកន្លែងធ្វើការ សមភាពយេនឌ័រ និង កិច្ចសន្ទនាសង្គម មកធ្វើជាមូលបទ។

ទិដ្ឋភាពដែលគួរអោយព្រួយបារម្ភជាងគេនៃឱនភាពការងារទំនងជា ផលប៉ះពាល់របស់វាទៅលើយុវជន។ នៅឆ្នាំ ២០០៥ អាស៊ីមានយុវជនច្រើនជាង ៤៨% ឬ ៤១,៦ លាននាក់ នៃយុវជនសរុបទូទាំងពិភពលោកដែលគ្មានការងារធ្វើ។ ឱកាសនៃភាពគ្មានការងារធ្វើរបស់យុវជនក្មេងៗ ស្មើនឹងយ៉ាងហោចណាស់ ៣ ដងច្រើនជាងមនុស្សពេញវ័យ។

## ***សេដ្ឋកិច្ច និង ទីផ្សារការងាររបស់អាស៊ី និង ប៉ាស៊ីហ្វិក***

បញ្ហាប្រឈមផ្សេងទៀតសំរាប់ការងារថ្លៃថ្នូរ ដែលបានរកឃើញដោយអង្គការពលកម្មអន្តរជាតិ រួមមានៈ

***កំណើនប្រាក់ឈ្នួល ដើរតាមក្រោយកំណើនផលិតភាព:*** នៅក្នុងប្រទេសចិន ផលិតភាពការងារនៅក្នុងវិស័យឧស្សាហកម្ម កើនឡើង ១៧០% នៅរវាងឆ្នាំ ១៩៩០ និង ១៩៩៩ ខណៈពេលដែលប្រាក់ឈ្នួលពិតកើនឡើង តិចជាង ៨០%។ ប្រទេសប៉ាគីស្ថាន និង ឥណ្ឌា បានធ្លាក់ចុះអត្រាប្រាក់ឈ្នួលពិតប្រាកដនៅក្នុងឧស្សាហកម្ម តាំងពី ឆ្នាំ ១៩៩០ មកម្ល៉េះ - ដែលប៉ាគីស្ថានធ្លាក់ចុះចំនួន ៨,៥% ហើយ ឥណ្ឌាធ្លាក់ចុះ ២២%។ ការធ្លាក់ចុះប្រាក់ឈ្នួល របស់ប្រទេសឥណ្ឌាកើតឡើង ទោះបីជាផលិតភាពការងារឧស្សាហកម្មកើនឡើង ៨៤% ក្នុងរយៈពេលតែមួយនេះក៏ដោយ ដែលនេះឆ្លុះបញ្ចាំងពីការធ្លាក់ចុះជីវភាពរស់នៅរបស់កម្មករនិយោជិត ទោះបីជាមានកំណើនប្រសិទ្ធិភាព ខាងការងាររបស់ពួកគេក៏ដោយ ។

- ***រយៈពេលធ្វើការវែង:*** កំណើនផលិតភាពខ្ពស់ ពុំមានន័យថា ម៉ោងធ្វើការមានរយៈខ្លីជាងមុននោះទេ។ សេដ្ឋកិច្ចចំនួន ៦ ដែលស្ថិតនៅលំដាប់កំពូលក្នុងពិភពលោក ខាងចំនួនម៉ោងធ្វើការប្រចាំឆ្នាំ សុទ្ធតែជាប្រទេសនៅអាស៊ីទាំងអស់គឺ បង់ក្លាដេស  ហុងកុង(ចិន) ម៉ាឡេស៊ី  សាធារណៈរដ្ឋកូរ៉េ  ស៊ីរីលង្ការ  ថៃ ហើយមនុស្សមួយផ្នែកធំធ្វើការងារ ៥០ ម៉ោង ឬ ច្រើនជាងនេះ ក្នុងមួយសប្តាហ៍។

- ***វិសមភាពរវាងភេទ:*** ទោះបីជាមានវឌ្ឍនភាពនៅក្នុងរយៈពេល ១៥ ឆ្នាំចុងក្រោយនេះក៏ដោយ ក៏គំលាតនៅតែមាន។ កម្មការនីដែលធ្វើការតាមរោងចក្រនៅប្រទេសសឹង្ហបុរី រកចំណូលបានជាមធ្យមស្មើនឹង ៦១% នៃចំណូលដែលកម្មករបុរសរកបានតែប៉ុណ្ណោះ ខណៈពេលដែលនៅក្នុងឆ្នាំកន្លងទៅថ្មីៗនេះ គំលាតយេនឌ័រនៃប្រាក់ឈ្នួលនៅក្នុងឧស្សាហកម្មបានថយចុះនៅក្នុងប្រទេសមួយចំនួន ដូចជា ជប៉ុន ម៉ាឡេស៊ី និង សាធារណៈរដ្ឋកូរ៉េ។

- ***កំណើនចល័តភាពរបស់កម្មករនិយោជិត:*** នៅក្នុងប៉ុន្មានឆ្នាំកន្លងទៅថ្មីៗនេះ កម្មករពី ២,៦ ទៅ ២,៩ លាននាក់នៅអាស៊ីបានចាកចោលស្រុកកំណើតជារៀងរាល់ឆ្នាំ ទៅធ្វើការនៅបរទេស។ ជាង ៥០% នៃអ្នកធ្វើចំណាកស្រុកមកពីអាស៊ីខាងត្បូង (ឥណ្ឌា បង់ក្លាដេស ប៉ាគីស្ថាន និង ស៊ីរីលង្ការ) ហើយក្រៅពីនេះ ភាគច្រើនមកពី ឥណ្ឌូនេស៊ី និង ហ្វីលីពីន។ ផ្ទុយកាលពីអតីតកាល នាពេលបច្ចុប្បន្ននេះអាស៊ីស្រូបយកកម្មករចំណាកស្រុកកាន់តែច្រើនឡើង ប្រមាណចំនួន ៤០%។

- ***ការធ្លាក់ចុះពលកម្មកុមារមិនស្មើគ្នា:*** នៅចន្លោះឆ្នាំ ២០០០ និង ២០០៤ ចំនួនកម្មករជាកុមារអាយុពី ៥ ដល់ ១៤ ឆ្នាំ ធ្លាក់ចុះចំនួន ៥ លាននាក់ នៅអាស៊ី និង ប៉ាស៊ីហ្វិក ប៉ុន្តែតំបន់ទាំងមូលនៅមានកម្មករជា កុមារប្រមាណ ១២២,៣ លាននាក់ទៀត ដែលស្មើនឹង ៦៤% នៃចំនួនកម្មករជាកុមារសរុប នៅក្នុង សកលលោក។

- ***សុវត្ថិភាព និង សុខភាពរបស់កម្មករនិយោជិត:*** កម្មករប្រមាណ ១ លាននាក់ បានស្លាប់ជារៀងរាល់ឆ្នាំនៅអាស៊ី ដោយសារគ្រោះថ្នាក់ និង ជំងឺឈឺស្កាត់ ដែលទាក់ទងនឹងការងារ។ ជំងឺដែលជាក្តីព្រួយបារម្ភធំជាងគេគឺជំងឺអេដស៍ ប្រមាណ ៩៧% នៃមនុស្សដែលមានជំងឺអេដស៍មានអាយុពី ១៥-៤៩ ឆ្នាំ ដែលជាក្រុមមនុស្សមានផលិតភាពច្រើនជាងគេ ដែលនេះបញ្ជាក់ពីផលប៉ះពាល់យ៉ាងធ្ងន់ធ្ងររបស់ជំងឺនេះមកលើកំលាំងការងារដែលពោរពេញទៅដោយផលិតភាព។

- ***សិទ្ធិនៅកន្លែងធ្វើការ:*** ខណៈពេលដែលប្រទេសជាច្រើន បានពង្រឹងច្បាប់ជាតិរបស់ខ្លួន អោយស្របទៅនឹងគោលការណ៍ និង សិទ្ធិជាមូលដ្ឋាននៅកន្លែងធ្វើការ (ជាពិសេស ទាក់ទងនឹងការរើសអើងនៅកន្លែង ធ្វើការ ពលកម្មកុមារ និង ពលកម្មដោយបង្ខំ) ព្រឹត្តិការណ៍ដែលកើតមានឡើងនៅក្នុងប្រទេសមួយចំនួន កាលពីពេលថ្មីៗនេះ ឆ្លុះបញ្ចាំងពីការគំរាមកំហែងយ៉ាងធ្ងន់ធ្ងរលើសេរីភាពនៃការចូលរួមក្នុងសមាគម។

- ***កំណើនគំលាតនៃភាពជាតំណាង:*** សមាជិកភាពសហជីពមានចាប់ពី ៣% ទៅ ៨% នៃកំលាំងការងារសរុប នៅក្នុងប្រទេសនានា ដូចជា បង់ក្លាដេស ថៃ ម៉ាឡេស៊ី និង សាធារណៈរដ្ឋកូរ៉េ និង ពី ១៦% ទៅ ១៩% នៅក្នុងប្រទេសញូហ្សេលេន អូស្ត្រាលី និង សឹង្ហបុរី ។ "ដង់ស៊ីតេ" សហជីពមានកំរិតទាបជាងគេ នៅក្នុងបណ្តាប្រទេសដែលមានវិស័យក្រៅផ្លូវការ និង កសិកម្មធំ ប៉ុន្តែបានធ្លាក់ចុះនៅក្នុងប្រទេសភាគច្រើនរបស់តំបន់នេះ ។ អង្គភាពនិយោជកបានជួបប្រទះនឹងបញ្ហាប្រឈមផងដែរ ដូចជាកំណើននៃភាពចំរុះរបស់ ក្រុមហ៊ុន និង កំណើនវត្តមាននៃក្រុមហ៊ុនពហុជាតិ ដែលជារើយៗមិនជាប់ពាក់ព័ន្ធនឹងសហព័ន្ធរបស់ជាតិ ។

ប្រឈមជាមួយនឹងបញ្ហាទាំងនេះ និង ឱនភាពដទៃទៀត របាយការណ៍នេះកត់សំគាល់ថា មានការគាំទ្រយ៉ាងទូលំទូលាយដល់ "របៀបវារៈការងារថ្លៃថ្នូរ" របស់អង្គការពលកម្មអន្តរជាតិ ហើយ លើកឡើងពីវឌ្ឍនភាពនានាដែលសំរេចបាន ចាប់តាំងពីកិច្ចប្រជុំប្រចាំតំបន់អាស៊ីរបស់អង្គការពលកម្មអន្តរជាតិកាលពីលើកមុន ក្នុងការគ្រប់គ្រងកំលាំងសកលភាវូបនីយកម្ម ជាពិសេសតាមរយៈផែនការសកម្មភាពជាតិសំរាប់ការងារថ្លៃថ្នូរ ។

លោក Somavia បានមានប្រសាសន៍ថា "នៅក្នុងរយៈពេលដែលមានភាពជ្រួលច្របល់ និង ការផ្លាស់ប្តូរយ៉ាងឆាប់រហ័សនេះ ពិភពលោកកំពុងសំលឹងមើលអាស៊ី ជាឧទាហរណ៍ និង ការអនុវត្តន៍ល្អ ពីរបៀបច្បាមយកកាលានុវត្តភាព និង ដោះស្រាយបញ្ហាប្រឈមនានាដែលបង្កឡើងដោយសកលភាវូបនីយកម្ម និង ការប្រកួតប្រជែងកាន់តែខ្លាំងឡើង និង ការរីកចំរើនខាងបច្ចេកវិទ្យា ។ ជាមួយនឹងការងារថ្លៃថ្នូរ ដែលឥលូវនេះត្រូវបានគាំទ្រជាគោលដៅសកល  កិច្ចការចំបងគឺត្រូវធ្វើអោយគោលដៅនេះក្លាយជាការពិត ហើយអាស៊ីមានសក្តានុពលជាអ្នកនាំមុខគេ ។ ការគាំទ្រយ៉ាងទូលំទូលាយលើគោលដៅការងារថ្លៃថ្នូរ គឺជាការទទួលស្គាល់ថា "ពាណិជ្ជកម្ម ជាធម្មតា" នឹងបង្កើតនូវចំនួនការងារដែលប្រជាពលរដ្ឋត្រូវការ ឬ ការងារប្រកបដោយគុណភាព ដែលអាចដោះស្រាយអតុល្យភាពដ៏ជ្រៅនេះ និង អាចរំដោះប្រជាពលរដ្ឋពីភាពក្រីក្របាន ។"

សំរាប់ព័ត៌មានបន្ថែម សូមមើលវ៉ិបសាយ www.ilo.org/asia ឬ ទាក់ទងក្រុមការងារទាក់ទងរបស់ អង្គការពលកម្មអន្តរជាតិ  Sophy Fisher, fisher@ilo.org, +82 1086598535; Thomas Netter, netter@ilo.org; Karen Naets-Sekiguchi, naets-sekiguchi@ilo.org

*អង្គការពលកម្មអន្តរជាតិរៀបចំកិច្ចប្រជុំប្រចាំតំបន់អាស៊ី និង តំបន់ដទៃទៀត នៅក្នុងពិភពលោក ដើម្បីដោះស្រាយបញ្ហាប្រឈម និង បញ្ហានានាដែលពិភពការងារកំពុងប្រឈម និង ដើម្បីពិនិត្យឡើងវិញលើសកម្មភាពនានារបស់អង្គការពលកម្មអន្តរជាតិ ។ គណៈប្រតិភូក៏នឹងទទួលរបាយការណ៍មួយពីសកម្មភាព របស់អង្គការពលកម្មអន្តរជាតិ នៅអាស៊ី និង ប៉ាស៊ីហ្វិក កំឡុង ៥ ឆ្នាំចុងក្រោយផងដែរ ។ អង្គការពលកម្មអន្តរជាតិគឺជាអង្គការត្រីភាគី ដែលកិច្ចប្រជុំរបស់អង្គការនេះ ចូលរួមដោយប្រតិភូមកពីរដ្ឋាភិបាល និយោជក និង និយោជិត ដែលពួកគេទាំងអស់សុទ្ធតែមានសិទ្ធិក្នុងការបោះឆ្នោត ។*